**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

******

**សាលាដំបូងខេត្តព្រះវិហារ**

.....

សំណុំរឿងព្រហ្មទណ្ឌលេខៈ ៧០
ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៩
សំណុំរឿងជំនុំជម្រះលេខៈ ៣៣
ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០
សាលក្រមព្រហ្មទណ្ឌលេខៈ១៧(ឍ)
ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០

# <u>តាងនាមប្រជារាស្ត្រខ្មែរ</u>

# <u>សាលាដំបូងខេត្តព្រះវិហារ</u>

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង០២ និង៣០នាទី រសៀល លើសំណុំរឿងព្រហ្មទណ្ឌលេខៈ៧០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០២០ ដោយមានសមាសភាពតុលាការនាពេលសវនាការ និងប្រកាសសាលក្រមដូចតទៅ:

## <u>ចៅក្រមជំនុំជម្រះ</u>

លោកស្រី [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមក្រុមប្រឹក្សា
លោក [redacted] ចៅក្រមក្រុមប្រឹក្សា

## <u>តំណាងអយ្យការ</u>

លោកស្រី [redacted] តំណាងអយ្យការអមសាលាដំបូងខេត្តព្រះវិហារ

## <u>ក្រឡាបញ្ជីសវនាការ</u>

លោក [redacted] ជាក្រឡាបញ្ជីសវនាការនៃសាលាដំបូងខេត្តព្រះវិហារ

## <u>មេធាវី</u>

លោក [redacted] ជាមេធាវីការពារឲ្យជនជាប់ចោទ
លោក [redacted] ជាមេធាវីការពារឲ្យជនជាប់ចោទ
លោក [redacted] ជាមេធាវីការពារឲ្យជនជាប់ចោទ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខៈ ៧០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ:

១-ឈ្មោះ[redacted]ទិត្យ ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត ភូមិ[redacted]ខេត្តព្រះវិហារ ទីលំនៅបច្ចុប្បន្ន ភូមិរ[redacted] ខេត្តព្រះវិហារ ម្តាយឈ្មោះ[redacted] ធី (រ) ប្រពន្ធឈ្មោះ[redacted]គា (រ) ជានីតិជន ទោសពីមុនគ្មាន។

២- ឈ្មោះ[redacted]ណែត ឬ [redacted]ណែត ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត ភូមិ[redacted] ខេត្តកំពត ទីលំនៅបច្ចុប្បន្ន ភូមិរលំ[redacted] ខេត្តព្រះវិហារ ឪពុកឈ្មោះ[redacted]ហាយ (រ) ម្តាយឈ្មោះ[redacted] បុល ប្រពន្ធទី១ឈ្មោះ[redacted] រាំភើយ កូន០១នាក់ និងប្រពន្ធទី២ឈ្មោះភា មានកូន០១នាក់ ជានីតិជន ទោសពីមុនគ្មាន។



Scanned with CamScanner

ណែត។ ខ្លួនបានស្គាល់ឈ្មោះ ណែត ជាលើកទី១នោះទេ បានស្គាល់ឈ្មោះ ណែត តាមទូរស័ព្ទ មិនដែលឃើញមុខ និងមិនចាំលេខវាច្បាស់ទេដឹងថាវាប្រើប្រព័ន្ធ០៩៧។ ខ្លួនបានទិញគ្រឿងញៀនពីឈ្មោះ ណែត តម្លៃក្នុង០១ថង់ចំនួន ម្ភៃម៉ឺនរៀល សរុបទាំងអស់ទិញចំនួន ០៨ ថង់ ប៉ុន្តែខ្លួនមិនទាន់ឲ្យលុយទៅអ្នកលក់ឡើយ ចំពោះថ្នាំ (WY)ទិញក្នុងតម្លៃ ០១គ្រាប់ ចំនួន ២,៥០០៛ (ពីរពាន់ប្រាំរយរៀល) ហើយលក់ចេញវិញក្នុងតម្លៃ ៥,០០០៛ (ប្រាំពាន់រៀល)។ ខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀនរយៈពេល ០៥ ទៅ ០៦ខែ តែប៉ុណ្ណោះមិនចាំខែឆ្នាំគឺប្រើប្រាស់ជាប់រហូត ខ្លួនចេះប្រើវាតាមមិត្តភក្តិហៅទៅសាក លុះខ្លួនចេះប្រើបាន០៤ខែ ក៏ចេះទាញផលប្រយោជន៍ពីគ្រឿងញៀន ពោលគឺលើកទី១៖ ខ្លួនបានទៅទិញគ្រឿងញៀនពីមនុស្សមិនស្គាល់បានចំនួន០២ដង ក្នុងម្តងៗ ២០០,០០០៛ (ម្ភៃម៉ឺនរៀល) និងលក់វិញបាន ៣០០,០០០ (សាមសិបម៉ឺនរៀល) ,លើកទី២៖ យកពីអ្នកមិនស្គាល់ដូចមុនលក់ឲ្យទៅអ្នកឡើងកាប់ឈើ និងលើកទី០៣៖ ទិញពីឈ្មោះ ណែត ភេទប្រុស ដោយស្គាល់លេខតាមរយៈអ្នកទិញគ្រឿងញៀនពីលើកមុន ។ ការដោះដូរគ្រឿងញៀនរវាងខ្លួននិងឈ្មោះ ណែត ពេលខ្លះគេយកឲ្យមកផ្ទាល់តែពាក់មុកការពារ ខ្លះដោយប្រយោល ដោយផ្លុងចោលនៅតាមផ្លូវ ខ្លួនបានចាប់ផ្តើមទាក់ទងគ្នាតាមទូរស័ព្ទថាចង់បានគ្រឿងញៀនពី ០៤ ទៅ ០៥កញ្ចប់ ឈ្មោះ ណែតបានតបតាមទូរស័ព្ទថា "មាន" ចាំដាក់ផ្លុងចោលតាមផ្លូវឲ្យ ខ្លួនត្រូវបានមិត្តភក្តិប្រាប់ថាឈ្មោះ ណែត មាននាមត្រកូល [redacted] ណែត មាឌធំខ្ពស់ ស្រុកកំណើតនៅខេត្តកំពត តែមករកស៊ីនៅស្រុកជាំក្សាន្ត ប្រពន្ធឈ្មោះ [redacted] រ៉ាភើយ មិនដឹងថាប្រពន្ធចុងឬដើមឡើយ។ ក្រោយពីបានគ្រឿងញៀនរំលងបានមួយថ្ងៃ ខ្លួនបានយកទៅចែកចាយ និងលក់បន្តនៅកន្លែងកាត់សក់ នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៩ ម៉ោងប្រហែល ០២ រសៀល ដោយទាក់ទងទៅអ្នកទិញតាមទូរស័ព្ទនិងលក់បាន ០២កញ្ចប់តូច តម្លៃ ១០០,០០០៛ (ដប់ម៉ឺនរៀល) ភ្លាមនោះត្រូវបានសមត្ថកិច្ចចុះមកឃាត់ខ្លួនបានភ្លាមៗ ដោយឆែកឃើញគ្រឿងញៀននៅក្នុងកាបូបស្ពាយរបស់ខ្លួនពិតមែន ហើយខ្លួនមិនមានជញ្ជីងសម្រាប់ថ្លឹងលក់នោះទេ គឺរំលែកស្មានចែកដោយដៃផ្ទាល់។ ពេលចាប់ឃាត់ខ្លួន សមត្ថកិច្ចបានចាប់ដកហូតបានគ្រឿងញៀន **ចំនួន២៣ កញ្ចប់** និងថ្នាំគ្រាប់ពណ៌ផ្កាឈូក **(WY) ចំនួន ៦០គ្រាប់**។ ចំពោះឈ្មោះ [redacted] ណែត នៅមុខសវនាការនេះគឺមិនមែនឈ្មោះ ណែត ដែលខ្លួនទិញគ្រឿងញៀននោះទេ និងមិនធ្លាប់បានទិញគ្រឿងញៀនពីគាត់ឡើយ។ ខ្លួនសុំទទួលស្គាល់ចម្លើយដែលបានឆ្លើយក្នុងដំណាក់កាល មន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការ និងចៅក្រមស៊ើបសួរ ជាចម្លើយរបស់ខ្លួន ពិតមែន។

-ជនជាប់ចោទឈ្មោះ [redacted] ណែត បានឆ្លើយសារភាពនៅមុខសវនាការថា៖ ខ្លួនមានអាយុ២៥ឆ្នាំ កើតនៅឯខេត្តកំពត ឪពុកឈ្មោះ ហាយ ប្រពន្ធទី១ឈ្មោះ សីហា (ហៅភើយ) ប្រពន្ធទី២ឈ្មោះ ភា មុខរបរធ្វើស្រែ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] ទិត្យ និងមិនបានលក់គ្រឿងញៀនទៅគាត់ដូចការចោទប្រកាន់ឡើយ។ ខ្លួនត្រូវបានជាប់ឃុំក្នុងសំណុំរឿងផ្សេងទាក់ទងនឹងបទល្មើសគ្រឿងញៀន ត្រូវឃាត់ខ្លួននៅថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១៩ ដោយពេលនោះខ្លួនបានជិះម៉ូតូទៅទិញគ្រឿងញៀនពីឈ្មោះ[redacted]វដ្ឋា ចំនួន០៣ កញ្ចប់ ហើយត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនបានភ្លាមៗ។ ឈ្មោះ [redacted] វដ្ឋា នេះឥឡូវកំពុងជាប់ឃុំក្នុងពន្ធនាគារដូចខ្លួនដែរ។ ខ្លួនធ្លាប់បានទិញគ្រឿងញៀនពីឈ្មោះ ខាងលើបានចំនួន០៤ដង លើកទី១៖ទិញអស់ ១០០,០០០៛ (ដប់ម៉ឺនរៀល), ទី២៖ ទិញអស់ ៦០,០០០៛ (ប្រាំមួយម៉ឺនរៀល), ទី៣៖ ទិញអស់ ១០០$ (មួយរយដុល្លា) និងលើកទី៤ ត្រូវបានសមត្ថកិច្ចចាប់ខ្លួនបានតែម្តង។ រាល់ពេលទិញលក់គ្រឿងញៀនម្តងៗគឺទៅយកឲ្យគេដោយផ្ទាល់ ឬទម្លាក់ទុកឲ្យគេតាមគុម្ពស្មៅក្បែរផ្លូវ ហើយខ្លួនមិនស្គាល់អ្នកទិញ

ក្នុងកាតបយកទៅឲ្យគេនៅកន្លែងកាត់សក់ លុះពេលយកទៅដល់ទីនោះជនសង្ស័យកំពុងតែប្រគល់គ្រឿងញៀន និងទទួលប្រាក់ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនបានភ្លាមៗ ពិតមែន ដូច្នេះ តំណាងអយ្យការសុំរក្សាការចោទប្រកាន់ដូចក្នុងដីកាដំណោះស្រាយបញ្ជូនមកជំនុំជម្រះនិងសុំឲ្យតុលាការសម្រេចផ្តន្ទាទោសទៅតាមច្បាប់កំណត់។

## <u>សេចក្តីសន្និដ្ឋានប្តឹងសុំមេធាវីការពារសិទ្ធិ</u>

ស្នុំសុំអោយតុលាការមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនឈ្មោះ [redacted] ទិត្យ ព្រោះគាត់បានដឹងកំហុស និងសុំបន្ធូរបន្ថយទោសលើកូនក្តីខ្លួនឈ្មោះ [redacted] ណៃត ព្រោះគាត់មិនបានធ្វើការជួញដូរគ្រឿងញៀនលក់ទៅឲ្យឈ្មោះ[redacted] ទិត្យ ពិតមែន។

## <u>សំដីចុងក្រោយរបស់ជនជាប់ចោទ</u>

-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ទិត្យស្នើសុំអោយតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង ចំណែកជនជាប់ចោទឈ្មោះ [redacted] ណៃត ស្នើសុំអោយតុលាការមេត្តាសម្រេចឲ្យរួចផុតពីបទចោទប្រកាន់មកលើខ្លួនដោយក្តីអនុគ្រោះ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទទាំងពីរនាក់

ក្រោយពីបានស្តាប់អំណានភស្តុតាងផ្សេងៗ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិ

ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសម្តីចុងក្រោយ

ក្រោយពីបានពិនិត្យភស្តុតាង

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សំអាងហេតុ</u>

១. កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ១៣ និង ៤០នាទី កម្លាំងការិយាល័យប្រឆាំងគ្រឿងញៀន នៃកងរាជអាវុធហត្ថខេត្តព្រះវិហារ បានចុះបង្ក្រាបករណី រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដោយឃាត់ខ្លួនជនសង្ស័យឈ្មោះ[redacted]ទិត្យ ភេទប្រុស អាយុ២៧ឆ្នាំ ដែលត្រូវបានឈ្មោះ ណៃត ភេទប្រុស ប្រើឲ្យយកថ្នាំញៀនដែលដាក់ក្នុងកាតបយកទៅឲ្យគេនៅកន្លែងកាត់សក់ លុះពេលយកទៅដល់ទីនោះជនសង្ស័យកំពុងតែប្រគល់គ្រឿងញៀន និងទទួលប្រាក់ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនបានភ្លាមៗ និងកសាងសំណុំរឿងមកកាន់តំណាងអយ្យការ ពិតមែន ។

២.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ទិត្យបានសារភាពថាៈ ខ្លួនពិតជាបានជួញដូរគ្រឿងញៀនដូចការចោទប្រកាន់ពិតប្រាកដមែន ហើយសមត្ថកិច្ចដកហូតបាន៖ម្សៅក្រាម ស ថ្លា ចំនួន ២៣កញ្ចប់ ស្មើនឹង៣១,១៨ ក្រាម (សាមសិបមួយក្បៀសដប់ប្រាំបីក្រាម) និងថ្នាំគ្រាប់ពណ៌ផ្កាឈូក (WY) ចំនួន ៦០គ្រាប់ ស្មើនឹង ៣,៦៧ ក្រាម (បីក្បៀសហុកសិបប្រាំពីរក្រាម) ទូរស័ព្ទ ០១គ្រឿង កាបូបស្ពាយចំនួន ០១ និងសម្ភារៈវេចខ្ចប់ប្រើប្រាស់មួយចំនួនទៀត ដែលជារបស់ខ្លួន ដូច្នេះតុលាការនឹងធ្វើការពិចារណាពីអំពើប្រព្រឹត្តក្នុងការសម្រេចនៃទោស។



Scanned with CamScanner

ល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៥ ចំណុច៦ និង មាត្រា ៤៥នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន បង្កឡើងដោយឈ្មោះ [redacted] ទិត្យ , និងបទល្មើសរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ភូមិរលំថ្ម ឃុំជាំក្សាន្តស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៥ ចំណុច៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន បង្កឡើងដោយឈ្មោះ [redacted] ណែត ឬ [redacted] ណែត ពិតប្រាកដមែន គប្បីតុលាការពិចារណា និងសម្រេច។

១២.សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទបានបញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការរក្សាទុក ដឹកជញ្ជូននិងជួញដូរ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនដែលធ្វើឲ្យប៉ះពាល់ដល់សុខភាពសេចក្តីថ្លៃថ្នូរ របស់មនុស្សជាតិ និងប្រទេសជាតិទាំងមូលពិតប្រាកដមែន ។

១៣.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ សន្តិសុខសង្គម ព្រមទាំងបូរណភាពបុគ្គលដែលច្បាប់ការពារ ។

១៤.ជនជាប់ចោទជានីតិជនដែលមាន សមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌពោលគឺ ពុំមានភស្តុតាងណាមួយបញ្ជាក់ថាជនជាប់ចោទមានបញ្ហាស្មារតីនោះទេ ដូច្នេះ ជានជាប់ចោទមានស្មារតីយល់ដឹងពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួន។

១៥.តាមពិតលើកំណត់ហេតុដកហូតសំណាក យកទៅធ្វើកោសលវិច័យគ្រឿងញៀនប្រភេទម្សៅក្រាមពណ៌សថ្លា មានទម្ងន់ ២៦,៨៥ ក្រាម (ម្ភៃប្រាំមួយក្បៀសប៉ែតសិបប្រាំក្រាម) មិនគិតទម្ងន់ថង់ ដែលមានធាតុសុទ្ធ ៧៩,៨៣%ដែលស្មើសារធាតុសរុបស្មើនឹង ២១,៤៣៨៣ ក្រាម , ចំណែកគ្រាប់ WY ចំនួន ៦១ គ្រាប់ ស្មើ ៤,៧៨ក្រាម (បួនក្បៀសចិតសិបប្រាំបីក្រាម) មានធាតុសុទ្ធ ១៥,៤២ % ដូចនេះស្មើនឹង ០,៧៣៧០ ក្រាមជាទម្ងន់សរុបរបស់សារធាតុញៀនពិតមែន។

១៦.មានពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទ ទី១/ឈ្មោះ [redacted] ទិត្យ ពីបទៈ រក្សាទុក ដឹកជញ្ជូន ឬជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ភូមិរលំថ្ម ឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៥ ចំណុច៦ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងទី២/ ឈ្មោះ [redacted] ណែ ឬ [redacted] ណែតពីបទៈរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិរលំថ្ម ឃុំជាំក្សាន្តស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៥ ចំណុច៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៧.វត្ថុតាងដកហូតបានមានៈ

.ម្សៅក្រាម ស ថ្លា ចំនួន ២៣ កញ្ចប់ ស្មើនឹង២៦,៨៥ ក្រាម ( ម្ភៃប្រាំមួយក្បៀសប៉ែតសិបប្រាំក្រាម) មិនគិតទម្ងន់ថង់

.ថ្នាំគ្រាប់ពណ៌ផ្កាឈូក(WY) ចំនួន៦១គ្រាប់ ស្មើនឹង ៤,៧៨ ក្រាម (បន្ទក្បៀសចិតសិបប្រាំបីក្រាម)

.ទូរស័ព្ទ ០១គ្រឿង ម៉ាកណូគា ពណ៌ខ្មៅ លាយផ្ទៃមេឃ (ចាស់)

.កាបូបស្ពាយចំនួន០១ ពណ៌ប្រផេះនិងសម្ភារៈវេចខ្ចប់ប្រើប្រាស់មួយចំនួនទៀត។



Scanned with CamScanner